# សន្ទរកថាគន្លឹះរបស់ឯកឧត្តមតូចប៊ុនហួរអគ្គលេខាធិការរង
# នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទក្នុងឱកាស
# សិក្ខាសាលាបញ្ចប់គម្រោងកសាងសមត្ថភាពសហគមន៍ដើម្បីកាត់បន្ថយភាពក្រីក្រ
# នៅតំបន់បឹងទន្លេសាប(JFPR 9114- CAM)

## នៅសណ្ឋាគារណាហ្គាវើល(NAGA WORLD)

## ភ្នំពេញថ្ងៃទី ២៦ខែមេសាឆ្នាំ២០១១

- ឯកឧត្តមលោកជំទាវលោក/ លោកស្រីជាទីគោរពរាប់អាន!
- ឯកឧត្តមលោកជំទាវលោក/ លោកស្រីភ្ញៀវកិត្តិយសអន្តរជាតិជាទីរាប់អាន!
- សូមគោរពអង្គសិក្ខាសាលាទាំងមូល!

ថ្ងៃនេះជាថ្ងៃប្រកបដោយនក្ខត្តិឫកនិងពោរពេញដោយមោទនៈភាពយ៉ាងរីករាយក្រៃលែងដោយបានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាបញ្ចប់គម្រោងកសាងសមត្ថភាពសហគមន៍ដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់បឹងទន្លេសាប (JFPR 9114- CAM)ដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិជប៉ុនសម្រាប់កាត់បន្ថយភាពក្រីក្រតាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ហើយដែលអនុវត្តដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទវិទ្យាស្ថានសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កម្ពុជា(CDRI)វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម(CBNRM-LI) ក្រោមការសម្របសម្រួលដោយផ្ទាល់ដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

ឯកឧត្តមលោកជំទាវលោក/ លោកស្រីភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិជាទីរាប់អាន!

ជាបឋមអនុញ្ញាតិឲខ្ញុំបាទរួមជាមួយនឹងអង្គសិក្ខាសាលាទាំងមូលចូលរួមសម្តែងនូវសេចក្តីទុក្ខក្រៀមក្រំចំពោះប្រជាជនជប៉ុនដែលបានទទួលរងគ្រោះរហូតដល់បាត់បង់អាយុ

ជីវិតដោយសារគ្រោះមហន្តរាយធម្មជាតិដែលបង្ករដោយព្យុះស៊ូណាមីនិងរញ្ជួយដីដ៏គួរឲរន្ធត់ក្រៃលែង។ខ្ញុំសូមឆ្លៀតយកឱកាសនេះចូលរួមរំលែកទុក្ខដល់ជនរងគ្រោះនៃប្រជាជនជប៉ុនទាំងអស់ព្រមទាំងបួងសួងឲជនរងគ្រោះបាត់បង់ជីវិតទាំងនោះបានទៅកាន់ភពថ្មីកុំបីខាន ។

ឆ្លៀតក្នុងឱកាសនេះដែរក្នុងនាមឯកឧត្តម**ឧបនាយករដ្ឋមន្ត្រីយឹមឆៃលី**ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទនិងក្នុងនាមខ្ញុំបាទផ្ទាល់ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលជប៉ុនដែលបានផ្តល់ហិរញ្ញប្រទានសហប្រតិបត្តិការជាជំនួយឥតសំណងដល់រាជរដ្ឋាភិបាលកម្ពុជាយ៉ាងច្រើនសម្រាប់ចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសក៏ដូចជាការកាត់បន្ថយភាពក្រីក្រនិងការរួមចំណែកដល់ដំណើរការអនុវត្តវិមជ្ឈការនិងវិសហមជ្ឈការនៅកម្ពុជាដែលជាក់ស្តែងគឺការផ្តល់ហិរញ្ញប្រទានដែលមានទឹកប្រាក់សរុបចំនួន១,៥ លានដុល្លាសហរដ្ឋអាមេរិកសម្រាប់អនុវត្តន៍កម្មវិធីកាត់បន្ថយភាពក្រីក្រនៅកម្ពុជាតាមរយៈការអនុវត្តគម្រោងកសាងសមត្ថភាពសហគមន៍ដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់បឹងទន្លេសាប (JFPR 9114- CAM)ដែលគម្រោងនេះបានចែកចេញជាបីសមាសភាគគឺការពង្រឹងសមត្ថភាពមូលដ្ឋានអនុវត្តដោយវិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម(CBNRM-LI)ការគ្រប់គ្រងនិងការផ្សព្វផ្សាយចំណេះដឹងសម្រាប់ការកាត់បន្ថយភាពក្រីក្រអនុវត្តដោយវិទ្យាស្ថានសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កម្ពុជា(CDRI)និងការពង្រឹងភាពជាដៃគូនិងការគ្រប់គ្រងចំណេះដឹងនិងព័ត៌មានអនុវត្តដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។ជាមួយគ្នានេះដែរក៏សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅដល់កិច្ចខិតខំប្រឹងប្រែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីជាពិសេសកញ្ញាNao Ikemotoគណៈប្រតិភូដឹកនាំបេសកកម្មនិងលោកDarryl Bullenទីប្រឹក្សាបច្ចេកទេសរបស់គម្រោងក្នុងកិច្ចសហការនិងសម្របសម្រួលដល់ការអនុវត្តគម្រោងនេះឲទទួលបានជោគជ័យគួជាទីមោទនៈ។

ឯកឧត្តមលោកជំទាវលោក/ លោកស្រីភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិជាទីរាប់អាន!

ខ្ញុំសូមបញ្ជាក់បន្ថែមថាក្រោយពីមានការព្រមព្រៀងគ្នាលើការអនុវត្តគម្រៀងរួចមកគម្រោងកសាងសមត្ថភាពសហគមន៍ដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់បឹងទន្លេសាប (JFPR 9114-CAM)នេះបានចាប់ផ្តើមអនុវត្តចាប់តាំងពីថ្ងៃទី៣១
ខែមករាឆ្នាំ២០០៨ហើយត្រូវបញ្ចប់នៅថ្ងៃទី៣១
ខែធ្នូឆ្នាំ២០១០។ម្យ៉ាងវិញទៀតដោយហេតុថាគម្រោងនេះបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដែលជាហេតុបណ្តាលឲមានការអូសបន្លាយពេលវេលាដូច្នេះគម្រោងក៏បានពន្យាពេលបន្តរយៈពេល០៥ខែទៀតគឺចាប់ពីខែធ្នូឆ្នាំ២០១០ដល់ខែមេសាឆ្នាំ២០១១។

ឯកឧត្តមលោកជំទាវលោក/ លោកស្រីភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិជាទីរាប់អាន!ខ្ញុំសូមអនុញ្ញាតិជម្រាបជូនពីគោលបំណងនៃសិក្ខាសាលានាថ្ងៃនេះគឺដើម្បីប្រមូលនូវរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តគម្រោងរបស់សមាសភាពទាំងបីចាប់តាំងពីពេលចាប់ផ្តើមរហូតមកទល់នឹងពេលបញ្ចប់នាពេលនេះរួមជាមួយនឹងការបង្ហាញពីបទពិសោធន៍បញ្ហាប្រឈមនិងដំណោះស្រាយមួយចំនួនសម្រាប់យកមកអនុវត្តគម្រោងដ៏ទៃទៀតដែលនឹងបង្ហាញដោយភ្នាក់ងារអនុវត្តទាំងបីដូចបានជម្រាបជូនខាងលើនាពេលបន្ទាប់ទៀត។

ជាថ្មីម្តងទៀតខ្ញុំសូមឲអង្គសិក្ខាសាលាទាំងមូលមេត្តាចូលរួមយកចិត្តទុកដាក់ក្នុងការពិនិត្យពិភាក្សានិងផ្តល់យោបល់ជុំវិញបទពិសោធន៍និងដំណោះស្រាយនានាពាក់ព័ន្ធនឹងការអនុវត្តគម្រោងនេះក្នុងន័យកែលម្អដើម្បីទុកជាបទពិសោធន៍សម្រាប់យកមកអនុវត្តនាពេលក្រោយទៀត។

ខ្ញុំសូមប្រកាសបើកអង្គសិក្ខាសាលានាថ្ងៃនេះចាប់ពីពេលនេះតទៅ។

សូមអរគុណ!